**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១១៧.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការដំឡើងស្ថានីយ៍ផលិតគ្រាប់ពូជទី១ ទៅជា វិទ្យាស្ថានជាតិស្រាវជ្រាវ និងអភិវឌ្ឍន៍ការីវប្បកម្មសម្តេចតេជោ ហ៊ុន សែន

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ /នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានឋានៈស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា ១.-**

ត្រូវបានដំឡើងស្ថានីយ៍ផលិតត្រីពូជទី១ ទៅជាវិទ្យាស្ថានជាតិស្រាវជ្រាវ និងអភិវឌ្ឍវារីវប្បកម្ម **សម្តេចតេជោ ហ៊ុន សែន** ដែលសរសេរជាអក្សរកាត់ថា វ.ជ.ហ.ស. មានឋានៈស្មើនាយកដ្ឋាន ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

វ.ជ.ហ.ស.មានទីតាំងស្ថិតនៅ ភូមិព្រែកឡុង ឃុំការខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ។

**មាត្រា ២.-**

វ.ជ.ហ.ស. មានតួនាទី និងភារកិច្ច ដូចតទៅ ៖

- សិក្សាស្រាវជ្រាវលក្ខណៈជីវសាស្ត្រ និងជ្រើសរើសពូជវារិជាត
- សិក្សាស្រាវជ្រាវបច្ចេកទេសថែបំប៉នមេពូជ ផលិត បង្កាត់ពូជវារិជាត
- សិក្សាស្រាវជ្រាវបច្ចេកទេសប្រើប្រាស់ថ្នាំ និងអរម៉ូនសម្រាប់វារិជាត
- សិក្សាស្រាវជ្រាវបច្ចេកទេសចិញ្ចឹមប្រភេទវារិជាត ដែលមានតម្លៃសេដ្ឋកិច្ច
- សិក្សាស្រាវជ្រាវបច្ចេកទេសផលិតប្រភេទវារិជាតមានដោយកម្រ ដែលជិតផុតពូជ
- សិក្សាស្រាវជ្រាវបច្ចេកទេសថែរក្សា ផលិតចំណីធម្មជាតិ និងចំណីសិប្បនិម្មិត
- សិក្សាស្រាវជ្រាវ និងបង្កើនសមត្ថភាពមន្ទីរពិសោធន៍ ផ្នែកវិភាគគុណភាពទឹក ចំណី ជំងឺវារិជាត និងវិធីសាស្ត្រព្យាបាល
- សិក្សាស្រាវជ្រាវនិងអភិរក្សសេនេទិកវារិជាត
- បណ្តុះបណ្តាល និងបំពាក់បំប៉នបច្ចេកវិទ្យាវារីវប្បកម្ម
- បង្កើតមូលដ្ឋានទិន្នន័យ ចងក្រងឯកសារ និងផ្សព្វផ្សាយព័ត៌មានបច្ចេកទេសវារីវប្បកម្ម
- ធ្វើសហប្រតិបត្តិការជាមួយអង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័ននានាក្នុងកិច្ចសហការស្រាវជ្រាវវារីវប្បកម្ម
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំរដ្ឋបាលជលផល ប្រគល់ឱ្យ ។

វ.ជ.ហ.ស.ដឹកនាំដោយ នាយកមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងអមដោយនាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៣.-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់វ.ជ.ហ.ស. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ ០២ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ